# អំណាចនៃបព្វជិតភាពអើរ៉ុន

*ដោយ ប៊ីស្សព យេស៍ ប៊ី ម៉ាក់មូលីន*
*ទីប្រឹក្សាទីពីរក្នុងគណៈប៊ីស្សពជាអធិបតី*

ក្នុងវគ្គហ្វឹកហ្វឺនថ្មីៗមួយសម្រាប់អ្នកមានសិទ្ធិអំណាចទូទៅ ប្រធានថូម៉ាស អេស ម៉នសុន បានសង្កត់ធ្ងន់ជាថ្មីម្តងទៀត ពីភារកិច្ច និងឱកាសសម្រាប់អ្នកកាន់បព្វជិតភាពអើរ៉ុន ។[1] ដោយនូវគោលបំណងដូចនឹងការណែនាំទាំងនោះដែរ ខ្ញុំសូមថ្លែងទៅកាន់អ្នក។

កាតព្វកិច្ចដែលត្រូវបានអនុវត្តដោយត្រឹមត្រូវ កំណត់ពីជោគវាសនារបស់មនុស្ស និងជាតិសាសន៍នានា ។ ដូច្នេះ គោលការណ៍គ្រឹះគឺជាគោលការណ៍នៃភារកិច្ចដែលអ្នកកាន់បព្វជិតភាពត្រូវបានទូន្មានថា « ហេតុដូច្នេះហើយ ឥឡូវនេះ ចូរឲ្យមនុស្សគ្រប់រូបរៀនពីភារកិច្ចរបស់ខ្លួន ហើយឲ្យប្រតិបត្តិក្នុងតំណែងដែលខ្លួនត្រូវបានតាំងឡើង ដោយសេចក្តីឧស្សាហ៍គ្រប់ជំពូក » ។[2]

ប្រធាន ម៉នសុន ពន្យល់ថា « ការហៅចំពោះភារកិច្ចអាចចូលមកដោយស្ងប់ស្ងៀម ដូចដែលយើងជាអ្នកកាន់បព្វជិតភាពឆ្លើយតបចំពោះការចាត់តាំងដែលយើងទទួលដែរ » [3] « វាជាភារកិច្ចរបស់អ្នក ក្នុងការរៀនពីអ្វីដែលព្រះអម្ចាស់មានព្រះទ័យជាមុនសិន ហើយបន្ទាប់មក ដោយអំណាច និងភាពរឹងមាំនៃបព្វជិតភាពដ៏បរិសុទ្ធរបស់ទ្រង់ អ្នកត្រូវតម្កើងការហៅរបស់អ្នកក្នុងចំណោមមិត្តភក្តិអ្នកតាមរបៀបមួយដែលមនុស្សនឹងរីករាយធ្វើតាមអ្នក » ។[4] និយាយពីភារកិច្ចរបស់ទ្រង់ ព្រះអម្ចាស់របស់យើងមានបន្ទូលថា ៖ « ខ្ញុំមិនរកតាមតែចិត្តខ្ញុំទេ គឺតាមព្រះហឫទ័យនៃព្រះវិញ… ។ ខ្ញុំបានចុះពីស្ថានសួគ៌មក មិនមែននឹងធ្វើតាមចិត្តខ្ញុំទេ គឺតាមបំណងព្រះហឫទ័យនៃព្រះវិញ ដែលទ្រង់បានចាត់ឲ្យខ្ញុំមក » ។[5] ដោយព្រោះព្រះយេស៊ូវគ្រីស្ទបានធ្វើភារកិច្ចទ្រង់ « នោះមនុស្សលោកទាំងអស់អាចបានសង្គ្រោះដោយសារការគោរពតាមក្រិត្យវិន័យ និងពិធីការទាំងឡាយនៃដំណឹងល្អ » ។[6] បងប្អូនប្រុស នេះជាបទដ្ឋានដែលយើងត្រូវតែធ្វើតាម ។

តាមបទពិសោធន៍ ខ្ញុំសង្កេតឃើញថា អ្នកដែលជាពួកឌីកុន ពួកគ្រូ និងពួកសង្ឃ មានឆន្ទៈអាចទុកចិត្តបាន និងមានសមត្ថភាពក្នុងការធ្វើតាមភារកិច្ចអ្នក តាមដែលយើងរំពឹងឲ្យអ្នកប្រែក្លាយ ។ យើងសរសើរដល់អ្នក ។ ភាពស្វាហាប់របស់អ្នកធ្វើឲ្យយើងស្វាហាប់ផងដែរ សមត្ថភាពអ្នកគឺអស្ចារ្យ យើងបានរឹងមាំតាមការទំនាក់ទំនងជាមួយអ្នក ។ អ្នក និងមុខតំណែងបព្វជិតភាពអើរ៉ុនដែលអ្នកកាន់ គឺចាំបាច់ដល់កិច្ចការព្រះបិតាសួគ៌ និងកូនចៅទ្រង់ និងដល់ការរៀបចំផែនដីនេះ សម្រាប់ការយាងមកជាលើកទីពីរនៃព្រះរាជបុត្រាទ្រង់ ។ ពេលយើងគិតពីអ្នក យើងមិនមើលឃើញតែពីអាយុអ្នកនោះទេ ។ ប៉ុលបាននិយាយពីអ្នកថា « កុំឲ្យអ្នកណាមើលងាយអ្នក ដោយព្រោះនៅក្មេងនោះឡើយ ចូរធ្វើជាគំរូដល់ពួកអ្នកជឿ ដោយពាក្យសំដី កិរិយាប្រព្រឹត្ត សេចក្តីស្រឡាញ់ សេចក្តីជំនឿ និងសេចក្តីបរិសុទ្ធ » ។[7]

*បព្វជិតភាពដាក់ឈ្មោះតាមអើរ៉ុន*
*បានមកដល់បុរសនាសម័យបុរាណ ។*
*តាម លេវី ជាសង្ឃ និងព្យាការីផង*
*ដើម្បីផ្តល់ពរដល់កូនចៅព្រះ ។*

*ហើយព្រះសង្គ្រោះបានយាងមក*
*ហើយបានស្វែងរកបុរសឈ្មោះយ៉ូហាន*
*ឲ្យជ្រមុជទឹកដោយអំណាចដដែលនេះ*
*ចាប់ផ្តើមកិច្ចការនៃសេចក្តីសង្គ្រោះ ។*

*នៅថ្ងៃចុងក្រោយ អំណាចដដែលនេះ*
*ត្រូវបានស្តារឡើងម្តងទៀត*
*ដើម្បីឲ្យអស់ទាំងការពិតនៃដំណឹងល្អ*
*បានចាក់ចូលក្នុងដួងចិត្តយើង ។*

*បព្វជិតភាពអើរ៉ុន ការពិតអស្ចារ្យ*

*មកដោយការរៀបចំ---*
*ដើម្បីមនុស្សអាចបានសង្គ្រោះ*
*ដោយព្រះរាជបុត្រាសំណព្វទ្រង់ !*

*ហើយអ្នកដែលប្រើអំណាចនេះ---*
*គ្រាន់តែជាក្មេងប្រុសអសមត្ថភាព ។*
*ដោយបព្វជិតភាពគ្របលើក្បាល*
*យើងថា « មើលនំ បុរស !»*[8]

« អំណាច និងសិទ្ធិអំណាចនៃ... បព្វជិតភាពអើរ៉ុន គឺត្រូវកាន់កូនសោទាំងឡាយនៃការងារបម្រើរបស់ពួកទេវតា ហើយដើម្បីចាត់ចែងការប្រព្រឹត្តខាងក្រៅទាំងឡាយ នៃពាក្យខាងដំណឹងល្អ បុណ្យជ្រមុជទឹកខាងការប្រែចិត្ត សម្រាប់ការផ្ដាច់បាបទាំងឡាយ យល់ព្រមតាមសេចក្ដីសញ្ញា និងព្រះបញ្ញត្តិទាំងឡាយ » ។[9] ប្រធាន ប៊យដ៍ យេ ផាកកឺ សង្កេតឃើញថា ៖ « យើងបានធ្វើយ៉ាងល្អ ក្នុងការចែកចាយនូវសិទ្ធិអំណាចបព្វជិតភាព ។ យើងស្ថាបនាសិទ្ធិអំណាចបព្វជិតភាពស្ទើរគ្រប់ទីកន្លែង...តែខ្ញុំគិតថា ការចែកចាយសិទ្ធិអំណាចបព្វជិតភាពបានទៅមុខមុនការចែកចាយអំណាចបព្វជិតភាព » ។[10] សម្រាប់ការសង្គ្រោះនៃកូនចៅព្រះ បញ្ហានេះត្រូវតែកែតម្រូវ ។

ព្យាការីរបស់យើងបានប្រាប់យើងពីរបៀបដែលយើងអាចកែបញ្ហានេះ ។ ប្រធានម៉នសុន បានមានប្រសាសន៍ថា ៖ « ខ្ញុំចង់ឃើញអំណាចបព្វជិតភាពត្រូវបានពង្រឹង ។ ...ខ្ញុំចង់ឃើញភាពរឹងមាំ ហើយអំណាចនេះ រីកសាយសព្វពាសពេញរាងកាយនៃអ្នកកាន់បព្វជិតភាពទាំងអស់ ចាប់ពីអ្នកដឹកនាំរហូតដល់...ឌីកុនដ៏រាបទាប និងអ្នកដែលតូចបំផុតក្នុងសាសនាចក្រ ។ បុរសគ្រប់រូបគប្បីស្វែងរក និងរីករាយនឹងវិវរណៈនៃព្រះ ជាពន្លឺនៃស្ថានសួគ៌ ដែលចែងចាំងក្នុងព្រលឹងគេ ហើយផ្ដល់ដល់គេនូវការចេះដឹងពីភារកិច្ចរបស់គេ ពីចំណែកកិច្ចការនោះ ដែលជាទំនួលខុសត្រូវរបស់គេក្នុងបព្វជិតភាព » ។[11]

តើឌីកុន គ្រូ ឬសង្ឃម្នាក់ អាចធ្វើអ្វីខ្លះ ដើម្បីទទួលវិញ្ញាណនៃវិវរណៈ និងដើម្បីតម្កើងការហៅរបស់គេ ? គេអាចរស់នៅតាមរបៀបមួយ ដែលគេអាចរីករាយ ជាមួយនឹងអំណាចនៃការសម្អាត ការញែកចេញ និងការបំភ្លឺមកពីព្រះវិញ្ញាណបរិសុទ្ធ ។

សារៈសំខាន់នៃការណ៍នេះ មានក្នុងពាក្យរបស់អាលម៉ា ៖ « ឥឡូវនេះ ខ្ញុំនិយាយទៅកាន់អ្នកថា នេះជាតំណែងដែលខ្ញុំបានទទួល ... ដើម្បីផ្សាយប្រាប់ ... ជំនាន់ដែលកំពុងពេញវ័យ ... ថា ពួកគេត្រូវប្រែចិត្ត ហើយកើតម្ដងទៀត » ។[12] ពេលមនុស្សម្នាក់កើតម្ដងទៀត ដួងចិត្តគេត្រូវបានផ្លាស់ប្ដូរ ។ គេគ្មានចំណង់ចង់ធ្វើការណ៍អាក្រក់ ឬមិនស្អាតស្អំឡើយ ។ គេមានក្ដីស្រឡាញ់ដ៏ជ្រាលជ្រៅ និងខ្ជាប់ខ្ជួនចំពោះព្រះ ។ គេចង់ធ្វើល្អ បម្រើអ្នកដទៃ និងរក្សាបទបញ្ញត្តិទាំងឡាយ ។[13]

ប្រធាន យ៉ូសែប  អេហ្វ ស្ម៊ីធ បានពណ៌នាពីបទពិសោធន៍របស់លោកជាមួយនឹងការផ្លាស់ប្ដូរដ៏ធំនេះថា ៖ « អារម្មណ៍ដែលចូលមកសណ្ឋិតលើខ្ញុំ ជាអារម្មណ៍នៃក្ដីសុខសាន្ត ក្ដីស្រឡាញ់ និងពន្លឺដ៏បរិសុទ្ធ  ។ ខ្ញុំបានដឹងក្នុងព្រលឹងខ្ញុំថា បើខ្ញុំបានធ្វើបាប...នោះខ្ញុំបានអភ័យទោសហើយ ថាខ្ញុំពិតជាបានត្រូវសម្អាតពីបាប ខ្ញុំរំជួលចិត្ត ហើយខ្ញុំមានអារម្មណ៍ថា ខ្ញុំមិនចង់ធ្វើឲ្យមានរបួស សូម្បីតែដល់សត្វល្អិតតូចបំផុតនៅក្រោមជើងខ្ញុំ ។ ខ្ញុំមានអារម្មណ៍ចង់ធ្វើល្អគ្រប់ទីកន្លែង ដល់មនុស្សគ្រប់គ្នា និងគ្រប់ការណ៍ទាំងអស់ ។ ខ្ញុំស្គាល់ជីវិតថ្មី បំណងថ្មី ដើម្បីធ្វើអ្វីដែលត្រូវ ។ ពុំមានបំណងអាក្រក់មួយភាគតូចណាមួយនៅសល់ក្នុងព្រលឹងខ្ញុំឡើយ ។ ខ្ញុំជាក្មេងប្រុសតូចម្នាក់ វាជាការពិត ... តែនេះជាឥទ្ធិពលដែលបានចូលមកសណ្ឋិតលើខ្ញុំ ហើយខ្ញុំដឹងថា វាមកពីព្រះ ហើយតែងតែជាទីបន្ទាល់ដ៏រស់រវើកដល់ខ្ញុំជានិច្ច ក្នុងការទទួលព្រះអម្ចាស់ ។[14]

ដូច្នេះ យើងហៅដល់អ្នក ជាប្អូនប្រុសវ័យក្មេងដ៏អស្ចារ្យ ឲ្យពុះពារដោយឧស្សាហ៍ដើម្បី « កើតជាថ្មី »។ [15] សូមអធិស្ឋានដើម្បីមានការផ្លាស់ប្ដូរដ៏ធំនេះក្នុងជីវិតអ្នក ។ ចូរសិក្សាព្រះគម្ពីរ ។ ចូរមានបំណងដើម្បីស្គាល់ព្រះ និងក្លាយដូចជាព្រះរាជបុត្រាដ៏បរិសុទ្ធទ្រង់ លើសជាងអ្វីៗទាំងអស់។ ចូររីករាយនឹងភាពជាយុវវ័យរបស់អ្នក តែចូរ « លះចោលការរបស់ក្មេងចេញទៅ » ៖[16]

ចៀសវាងការនិយាយប្រមាថ និងលីលា ។
ចេញពីគ្រប់ទាំងការណ៍អាក្រក់ ។
ចៀសវាងការឈ្លោះប្រកែក ។
ប្រែចិត្តពេលត្រូវការប្រែចិត្ត ។[17]

នេះនឹងជួយអ្នកលូតលាស់ទៅជាបុរសចាស់ទុំ និងថ្លៃថ្នូរ ។ គុណសម្បត្តិនៃក្តីក្លាហាន ភាពគួរទុកចិត្ត ការបន្ទាបខ្លួន ជំនឿ និងសេចក្តីល្អ នឹងជារបស់ផងអ្នក ។ មិត្តភក្តិ និងឪពុកម្តាយនឹងសរសើរអ្នក បងប្អូនប្រុសក្នុងបព្វជិតភាពនឹងពឹងពាក់អ្នក ហើយពួកស្រ្តីវ័យក្មេងនឹងស្រឡាញ់អ្នក ហើយនឹងកាន់តែក្លាយជាមនុស្សល្អ ដោយសារអ្នក ។ ព្រះនឹងប្រទានរង្វាន់ដល់អ្នក និងប្រទានអំណោយទានដល់ការបម្រើបព្វជិតភាពរបស់អ្នក ដោយព្រះចេស្តាពីស្ថានលើ ។

យើងទាំងអស់គ្នានឹងធ្វើផ្នែករបស់យើង ។ ក្នុងនាមជាឪពុកម្តាយ និងជីដូនជីតា យើងនឹងរៀបចំអ្នកសម្រាប់ការបម្រើដែលកាន់តែស្មោះត្រង់ ក្នុងនគរព្រះ ។ ក្នុងនាមជាបងប្អូនប្រុសរបស់អ្នក យើងនឹងធ្វើជាគំរូឲ្យអ្នកធ្វើតាម ។ យើងនឹងបង្កើនកម្លាំងនៃកូរ៉ុមរបស់អ្នក ។ យើងនឹងគាំទ្រ គណៈប្រធានកូរ៉ុមអ្នក ពេលពួកគេអនុវត្តកូនសោនៃអធិបតីរបស់គេ ។ យើងនឹងផ្តល់ឱកាសដល់អ្នក ដើម្បីបំពេញភារកិច្ចបព្វជិតភាពអើរ៉ុនឲ្យបានពេញលេញ និងដើម្បីតម្កើងការហៅរបស់អ្នកឡើង ។

តាមរយៈការបម្រើរបស់អ្នក នោះពរជ័យជាច្រើននឹងមានដល់សាសនាចក្រ ។ « ពួកទេវតានិយាយដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ » ។[18] អ្នកអាចធ្វើដូចគ្នាផងដែរ ។ ពេលអ្នកនិយាយដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ហើយចាត់ចែងនំប៉័ង និងទឹក នោះបុរស និងស្ត្រី ក្មេងប្រុស និងក្មេងស្រី នឹងព្យាយាមប្រែចិត្ត ដើម្បីបង្កើនក្តីជំនឿគេទៅលើព្រះគ្រីស្ទ ហើយដើម្បីមានព្រះវិញ្ញាណបរិសុទ្ធជាមួយគេជានិច្ច ។

ពេលអ្នកតមអាហារ និងប្រមូលដង្វាយតមអាហារ សមាជិកនឹងទទួលការបំផុសឲ្យធ្វើតាមគំរូនៃព្រះអង្គសង្គ្រោះ ។ ព្រះអម្ចាស់ខ្វល់ខ្វាយចំពោះអ្នកក្រីក្រ អ្នកត្រូវគេបៀតបៀន ហើយទ្រង់អញ្ជើញថា ៖ « ចូរមកតាមខ្ញុំចុះ » ។[19] ការបម្រើរបស់អ្នកក្នុងការខ្វល់ខ្វាយដល់អ្នកដែលខ្សត់ខ្សោយ ភ្ជាប់យើងទៅក្នុងកិច្ចការដ៏បរិសុទ្ធរបស់ទ្រង់ ហើយជួយយើងបន្តទទួលការអភ័យទោសចំពោះអំពើបាបពីមុនរបស់យើងផងដែរ ។[20]

ពេលអ្នក « ទៅផ្ទះនៃសមាជិកម្នាក់ៗ »[21] ចូរកុំភ័យខ្លាច ទាំងកុំខ្មាស់អៀនឡើយ ។ ព្រះវិញ្ញាណបរិសុទ្ធនឹងប្រទានដល់អ្នកនៅវេលានោះឯងនូវពាក្យដែលត្រូវនិយាយ ទីបន្ទាល់ដែលត្រូវថ្លែង ការបម្រើដែលត្រូវផ្តល់ ។

ការប្រឹងប្រែងដ៏ឧស្សាហ៍របស់អ្នកដើម្បី « មើលការខុសត្រូវលើសាសនាចក្រជានិច្ច »[22] នោះ នឹងផ្តល់ជាផ្លែផ្កាឡើង ។ អត្តចរិតដ៏រាបទាប និងស្មោះត្រង់របស់អ្នក នឹងបន្ទន់ចិត្តអ្នកដែលគ្មានជំនឿសោះ ហើយនឹងរបូតចេញពីកណ្តាប់ដៃរបស់សាតាំង ។ ការអញ្ជើញអ្នកដទៃឲ្យមកកាន់ព្រះវិហារជាមួយអ្នក ដើម្បីទទួលទានសាក្រាម៉ង់ជាមួយអ្នក និងដើម្បីបម្រើជាមួយអ្នក នឹងក្លាយជាពន្លឺដ៏អស្ចារ្យដល់ពួកអ្នកដែលបានបាត់ទៅក្នុងស្រមោល ដែលជាអ្នកមានពន្លឺនៃដំណឹងល្អ តែស្រអាប់ ឬមិនភ្លឺសោះតែម្តង ។

ឱ ប្អូនប្រុសវ័យក្មេងជាទីស្រឡាញ់របស់ខ្ញុំអើយ « កុំឲ្យធ្វេសនឹងអំណោយទានដែលសណ្ឋិតលើអ្នក »[23] ដែលអ្នកបានទទួលពេលគេប្រគល់ និងតែងតាំងអ្នកដល់បព្វជិតភាពអើរ៉ុនឡើយ ។

« ព្រះទ្រង់មិនបានប្រទានឲ្យយើងមានវិញ្ញាណ ដែលតែងតែខ្លាចឡើយ គឺឲ្យបានវិញ្ញាណដ៏មានអំណាច សេចក្តីស្រឡាញ់ និងប្រាជ្ញានឹងធឹងវិញ ។ មិនត្រូវឲ្យអ្នកមានសេចក្តីខ្មាស ចំពោះការធ្វើបន្ទាល់ពីព្រះអម្ចាស់នៃយើង ... ចូរទ្រាំទុក្ខលំបាក ... ក្នុងដំណឹងល្អ តាមព្រះចេស្តានៃព្រះចុះ ដែលទ្រង់បាន ... ហៅយើងមកក្នុងការងារបរិសុទ្ធ ... ដែលបានផ្តល់មកយើងក្នុងព្រះគ្រីស្ទយេស៊ូវ មុនអស់ទាំងកល្ប » ។[24]

ព្យាការីជាទីស្រឡាញ់របស់យើងបាន « ហៅអ្នកមកឯទង់នៃបព្វជិតភាព » ។[25] យើងគោរពអ្នក អធិស្ឋានសម្រាប់អ្នក រីករាយក្នុងការបម្រើជាមួយអ្នក និងថ្លែងអំណរគុណដល់ព្រះសម្រាប់អំណាចនៃការបម្រើក្នុងការសង្គ្រោះរបស់អ្នក ។

ខ្ញុំថ្លែងជាសាក្សីថា ព្រះគឺជាព្រះបិតាដ៏អស់កល្បជានិច្ចរបស់យើង ហើយទ្រង់គង់នៅឯស្ថានសួគ៌នាយ ។ ព្រះយេស៊ូវ ជាព្រះគ្រីស្ទ គឺជាព្រះរាជបុត្រាដ៏បរិសុទ្ធរបស់ព្រះ ជាអង្គប្រោសលោះនៃពិភពលោក ហើយអ្នករាល់គ្នាដែលកាន់បព្វជិតភាពអើរ៉ុន គឺជាសារទូតនៅលើផែនដី នៅក្នុងនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. ការបំពាក់បំប៉នពួកអ្នកដឹកនាំទូទៅ ខែ មេសា ឆ្នាំ 2010 ។

2. គោលលទ្ធិ និងសេចក្ដីសញ្ញា 107:99 ។

3. ថូម៉ាស អេស ម៉នសុន « The Sacred Call of Service » *Liahona* និង *Ensign* ខែ ឧសភា 2005 ទំព័រ 54 ។

4. George Albert Smith នៅក្នុង Conference Report ខែ មេសា ឆ្នាំ 1942 ទំព័រ 14 ។

5. យ៉ូហាន 5:30, 6:38 ។

6. មាត្រានៃសេចក្ដីជំនឿ 1:3 ។

7. ធីម៉ូថេទី1 4:12 ។

8. កំណាព្យដោយ Keith B. McMullin សូមមើល Keith B. McMullin « Behold the Man » *Ensign* ខែ វិច្ឆិកា ឆ្នាំ 1997 ទំព័រ 42 ។

9. គោលលទ្ធិ និងសេចក្ដីសញ្ញា 107:20 ។

10. Boyd K. Packer « The Power of the Priesthood » *Liahona* និង *Ensign* ខែ ឧសភា ឆ្នាំ 2010 ទំព័រ 7 ។

11. Thomas S. Monson, ការបំពាក់បំប៉នពួកអ្នកដឹកនាំទូទៅ ខែ មេសា ឆ្នាំ 2010 សូមមើល George Q. Cannon ក្នុង Conference Report ខែ តុលា 1889 ។

12. អាលម៉ា 5:49; សេចក្ដីដែលបានសង្កត់ធ្ងន់ត្រូវបានបន្ថែម ។

13. សូមមើល Marion G. Romney « According to the Covenants » *Ensign* ខែ វិច្ឆិកា ឆ្នាំ 1975 ទំព័រ 71--73 ។

14. Joseph F. Smith *Gospel Doctrine* កំណែទី5 ( ឆ្នាំ 1939 ) ទំព័រ 96 ។

15. យ៉ូហាន 3:3--7, អាលម៉ា 5:14--21 ទំព័រ 49 ។

16. កូរិនថូសទី1 13:11 ។

17. សូមមើល ធីម៉ូថេទី2 2:16, 22, 23 ។

18. នីហ្វៃទី2 32:3 ។

19. លូកា 18:22; សូមមើលផងដែរ យ៉ូហាន 14:12--14 ។

20. សូមមើល ម៉ូសាយ 4:26 ។

21. គោលលទ្ធិ និងសេចក្ដីសញ្ញា 20:47 ។

22. គោលលទ្ធិ និងសេចក្ដីសញ្ញា 20:53 ។

23. ធីម៉ូថេទី1 4:14 ។

24. ធីម៉ូថេទី2 1:7--9 ។

25. ប្រធានថូម៉ាស អេស ម៉នសុន ការបំពាក់បំប៉នពួកអ្នកដឹកនាំទូទៅ ខែ មេសា ឆ្នាំ 2010 ។